# ការអនុវត្តន៍ល្អ
## ការផ្តល់ទឹកស្អាតសំរាប់ពិសារ

រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

ទឹកស្អាតមានសារៈសំខាន់ណាស់សំរាប់កម្មករគ្រប់រូប ជាពិសេសនៅពេលធ្វើការងារក្នុងបរិយាកាសក្តៅ ហើយសើមដូចនៅប្រទេសកម្ពុជា ។ កំដៅបង្កឱ្យមានការខ្សោះជាតិទឹក ដែលបណ្តាលឱ្យអស់កំលាំង បាត់បង់ការផ្តង់ស្មារតីលើការងារ ព្រមទាំងបាត់បង់ផលិតភាព ។

### ការអនុវត្តន៍ល្អសំរាប់ការផ្តល់ទឹកពិសារមានអនាម័យ

- ត្រូវផ្តល់ទឹកពិសារមានអនាម័យគ្រប់គ្រាន់ដល់កម្មករ ។ ត្រូវដាក់ទឹកពិសារនៅក្នុងធុងដែលមានគំរប និងមានចំពួយបង្ហូរពីខាងក្រោម និងមិនរងនូវកំដៅព្រះអាទិត្យ (រូបភាពទី ១) ។
- ធុងដាក់ទឹកត្រូវដាក់នៅជិតកន្លែងការងារ ប៉ុន្តែដើម្បីរក្សាអនាម័យល្អ មិនត្រូវដាក់នៅជិតបង្គន់អនាម័យឡើយ (រូបភាពទី ១) ។
- ត្រូវផ្តល់កម្មករនូវកន្លែងទុកដាក់ពែង/កែវទឹកឱ្យបានត្រឹមត្រូវ ។ ទាំងនេះវានឹងធានាកុំឱ្យទឹកពិសារកំពប់នៅលើកន្លែងធ្វើការ (រូបភាពទី ២ និងទី ៣) ។
- គិតទុកមុនថា ការប្រើប្រាស់ទឹកមានការកើនឡើង អាស្រ័យទៅតាមចំនួនម៉ោងដែលធ្វើការ តាមចំនួនកម្មករនិយោជិត និងសីតុណ្ហភាពនៅខាងក្រៅ ។


រូបភាពទី១


រូបភាពទី២


រូបភាពទី៣

### អត្ថប្រយោជន៍:

- ✓ ជួយដល់កម្មករឱ្យមានថាមពលក្នុងអំឡុងពេលធ្វើការងារច្រើនម៉ោងក្នុងមួយថ្ងៃ ព្រមទាំងលើកស្ទួយផលិតភាព
- ✓ បន្ធូរបន្ថយការហត់នឿយ និងជំងឺការងារ ដូចជាការសន្លប់
- ✓ ស្ថានភាពសុខភាពរបស់កម្មករដែលល្អប្រសើរឡើងនឹងឈានដល់ការកាត់បន្ថយភាពអវត្តមាន

### តាមរបៀបណា:

- ✓ ត្រូវធ្វើកិច្ចសន្យាសេវាកម្មទឹកស្អាតជាមួយនឹងក្រុមហ៊ុនផ្គត់ផ្គង់ទឹកពិសារ
- ✓ ត្រូវរៀបចំកន្លែងទុកដាក់ទឹកពិសារឱ្យឆ្ងាយពីធូលី ពន្លឺព្រះអាទិត្យ សំរាម និងបង្គន់
- ✓ ត្រូវធានាថាកម្មករអាចប្រើប្រាស់ទឹកពិសារបានដោយគ្មានការដាក់កំហិតមិនសមហេតុផល
- ✓ ត្រូវលាងសំអាតធុងដាក់ទឹកជាប្រចាំ និងដូរពែង/កែវចាស់ៗចោល

### តំលៃ:

$

$ តំលៃទាប
$$ តំលៃមធ្យម
$$$ តំលៃខ្ពស់